**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១២៧៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ៣៩,៣៧១៦ ហិកតា នៅស្រុកឈូក ខេត្តកំពត ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១៧ គ្រួសារ និងមួយចំណែករក្សាទុកជាដីសាធារណៈរបស់រដ្ឋ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យ ប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ៧៤៩/១៦ល.ស ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៦ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត
- លិខិតលេខ ៣០២៥ ដនស/អសក ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៧ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- លិខិតលេខ ៤៧៧២ កសក ចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១** : ត្រូវបានកាត់ផ្ទៃដីទំហំ **៣៩,៣៧១៦ ហិកតា** ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១៧គ្រួសារ ទំហំ **៣៧,០០០៣ ហិកតា** និងផ្ទៃដីទំហំ **២,៣៧១៣ ហិកតា** រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិស្រែលាវ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា ២** : ត្រូវបានប្រគល់អាណាត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត ដើម្បីធ្វើការគ្រប់គ្រងនិងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ នៅភូមិស្រែលាវ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត ។

**មាត្រា ៣** : ក្នុងពេលដំណើរការវាស់វែង និងបែងចែកដាក់ស្តែងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពតត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤** : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ.....១២៥ អនក្រ.បក..........ចុះថ្ងៃទី.០៣....ខែ.សីហា.....ឆ្នាំ ២០១៧ស្តីពីការកាត់ដីទំហំ ៣៩.៣៧១៦ ហិកតា នៅភូមិស្រែលាវ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត ចេញពីគម្របព្រៃឈើឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១៧ គ្រួសារ កាន់កាប់ដាំដុះជាក់ស្តែង និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ




| ចំណុច | Y_PROJ | X_PROJ |
|---|---|---|
| 1 | 1200875 | 418825 |
| 2 | 1200871 | 418848 |
| 3 | 1200841 | 419018 |
| 4 | 1200833 | 419174 |
| 5 | 1200848 | 419179 |
| 6 | 1200879 | 419188 |
| 7 | 1200910 | 419195 |
| 8 | 1200960 | 419206 |
| 9 | 1200995 | 419215 |
| 10 | 1201029 | 419223 |
| 11 | 1201073 | 419234 |
| 12 | 1201125 | 419247 |
| 13 | 1201180 | 419257 |
| 14 | 1201252 | 419270 |
| 15 | 1201302 | 419276 |
| 16 | 1201378 | 419293 |
| 17 | 1201450 | 419304 |
| 18 | 1201537 | 419319 |
| 19 | 1201599 | 419331 |
| 20 | 1201590 | 419295 |
| 21 | 1201634 | 419264 |
| 22 | 1201676 | 419119 |
| 23 | 1201663 | 419045 |
| 24 | 1201651 | 419052 |
| 25 | 1201610 | 418924 |
| 26 | 1201593 | 418889 |
| 27 | 1201541 | 418860 |
| 28 | 1201407 | 418834 |
| 29 | 1201319 | 418579 |
| 30 | 1201264 | 418625 |
| 31 | 1201117 | 418732 |
| 32 | 1200989 | 418783 |
| 33 | 1200883 | 418821 |




**សញ្ញាសម្គាល់**

- ភូមិ
- ឃុំ
- ដីភ្នំ
- ព្រំប្រទល់ដីកាត់ចេញចំនួនសរុប ៣៩.៣៧១៦ ហិកតា
- ចំនុចគោល
- ការធ្វើប្រទានកម្មដីជូនប្រជាពលរដ្ឋចំនួន ៣៧.០០០៣ ហិកតា
- រក្សាទុកដីសាធារណៈរបស់រដ្ឋចំនួន ២.៣៧១៣ ហិកតា
- ស្ទឹង
- ផ្លូវ

**ទិន្នន័យគម្របព្រៃឈើ២០០២**

- ព្រៃស្រោង
- ព្រៃពាក់កណ្តាលស្រោង
- ព្រៃល្បោះ
- ដីគ្មានគម្របព្រៃ

Coordinate System Projection UTM Zone 48N Map Datum:WGS84

N

មាត្រដ្ឋាន 1:8,000

0 105 210 420 630 840 Meters

**ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ...១២៥ អនក្រ.បក.............ចុះថ្ងៃទី..០៣...ខែ..សីហា....ឆ្នាំ ២០១៧ស្តីពីការកាត់ដីទំហំ ៣៩,៣៧១៦ ហិកតា នៅភូមិស្រែលាវ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត ចេញពីគម្របព្រៃឈើឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១៧ គ្រួសារ កាន់កាប់ដាំដុះជាក់ស្តែង និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ**

N

មាត្រដ្ឋាន 1:10,000




| ចំណុច | Y_PROJ | X_PROJ |
|---|---|---|
| 1 | 1200875 | 418825 |
| 2 | 1200871 | 418848 |
| 3 | 1200841 | 419018 |
| 4 | 1200833 | 419174 |
| 5 | 1200848 | 419179 |
| 6 | 1200879 | 419188 |
| 7 | 1200910 | 419195 |
| 8 | 1200960 | 419206 |
| 9 | 1200995 | 419215 |
| 10 | 1201029 | 419223 |
| 11 | 1201073 | 419234 |
| 12 | 1201125 | 419247 |
| 13 | 1201180 | 419257 |
| 14 | 1201252 | 419270 |
| 15 | 1201302 | 419276 |
| 16 | 1201378 | 419293 |
| 17 | 1201450 | 419304 |
| 18 | 1201537 | 419319 |
| 19 | 1201599 | 419331 |
| 20 | 1201590 | 419295 |
| 21 | 1201634 | 419264 |
| 22 | 1201676 | 419119 |
| 23 | 1201663 | 419045 |
| 24 | 1201651 | 419052 |
| 25 | 1201610 | 418924 |
| 26 | 1201593 | 418889 |
| 27 | 1201541 | 418860 |
| 28 | 1201407 | 418834 |
| 29 | 1201319 | 418579 |
| 30 | 1201264 | 418625 |
| 31 | 1201117 | 418732 |
| 32 | 1200989 | 418783 |
| 33 | 1200883 | 418821 |

វាស់វែង ដោយប្រើឧបករណ៍ GPS MAP 62s

កំពត,ថ្ងៃទី...១៧....ខែ..តុលា....ឆ្នាំ២០១៦

អ្នកវាស់វែង

អ៊ីក ចាន់

លេខ៧១០.៩៤៦៨

បានឃើញ និងពិនិត្យត្រឹមត្រូវ

កំពត,ថ្ងៃទី...១៤....ខែ...តុលា...ឆ្នាំ២០១៦

ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកំពត

យឹន-វុឌ្ឍី

បានឃើញ និងឯកភាព

កំពត,ថ្ងៃទី...៣១...ខែ...តុលា...ឆ្នាំ២០១៦

អភិបាលខេត្ត និងជា

ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត

ចាន់ ចេស្តា

Coordinate System Projection UTM